Minnesota Department of Education

# សំណួរ និងចម្លើយអំពី ACCESS for ELLs និង Alternate ACCESS for ELLs

## តើ ACCESS for ELLs និង Alternate ACCESS for ELLs ជាអ្វី?

ACCESS for ELLs និង Alternate ACCESS for ELLs គឺជាការវាយតម្លៃពីភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស ដែលត្រូវបានយកមកប្រើដើម្បីឲ្យស្របទៅតាមភាពតម្រូវរបស់អង្គនីតិបញ្ញត្តិសហព័ន្ធ និងអង្គនីតិបញ្ញត្តិរដ្ឋ ។ ការវាយតម្លៃទាំងពីរបែបនេះ ត្រូវបានយកមកប្រើសម្រាប់ត្រួតពិនិត្យពីការរីកចម្រើនការសិក្សាភាសាអង់គ្លេសរបស់សិស្សដែលអង់គ្លេសមិនមែនជាភាសាកំណើតរបស់ខ្លួន ក្នុងពេលដែលពួកគេកំពុងតែអភិវឌ្ឍន៍បំណិនភាសាក្នុងការអាន ការសរសេរ ការស្តាប់ និងការនិយាយ ។

## ហេតុអ្វីបានជាយើងដាក់វិញ្ញាសារទាំងនេះឲ្យសិស្សប្រឡង?

ពិន្ទុចំពោះការប្រឡងវិញ្ញាសារ ACCESS for ELLs ព្រមទាំងវិញ្ញាសារ Alternate ACCESS for ELLs បានផ្តល់ព័ត៌មានដ៏មានប្រយោជន៍ អំពីការអភិវឌ្ឍន៍ភាសាអង់គ្លេស ដល់ក្រុមគ្រួសាររបស់សិស្ស និងសាលារៀន ។ ក្រុមគ្រួសាររបស់សិស្សអាចប្រើពិន្ទុបង្ហាញភាពស្ទាត់ជំនាញ ព្រមទាំងការពណ៌នាពីអត្ថន័យរបស់វា ដើម្បីយល់ដឹងអំពីភាពរីកចម្រើនផ្នែកភាសាអង់គ្លេសរបស់កូនខ្លួន និងសហការណ៍ជាមួយសាលាដើម្បីជ្រោមជ្រែងចំពោះការសិក្សាភាសារបស់កូនខ្លួន ។

គ្រូ និងសាលា អាចប្រើពិន្ទុនេះ សម្រាប់ត្រួតពិនិត្យពីការរីកចម្រើនរបស់សិស្សក្នុងការទទួលបានភាពស្ទាត់ជំនាញភាសាអង់គ្លេស ធ្វើផែនការបង្រៀន ព្រមទាំង សម្រាប់វាយតម្លៃកម្មវិធីបង្រៀនភាសាអង់គ្លេសរបស់សាលាខ្លួនទៀតផង ។ សាលាក៏អាចប្រើពិន្ទុទាំងនេះ កំណត់ថាតើសិស្សរបស់ខ្លួន អាចចាកចេញពីកម្មវិធីសិក្សាភាសាអង់គ្លេសបានហើយឬនៅ ។

លទ្ធផលការប្រឡងនៅកម្រិតសាលា និងកម្រិតមណ្ឌលសិក្សាស្រុក ត្រូវបានគេប្រើក្នុងការវាស់វែងគណនេយ្យភាពនៅថ្នាក់រដ្ឋ និងសហព័ន្ធ ។

## តើសិស្សណាដែលត្រូវប្រឡងវិញ្ញាសារទាំងនេះ?

សិស្សដែលជាអ្នកសិក្សាភាសាអង់គ្លេសទាំងអស់ ចាប់ពីថ្នាក់មតេយ្យ ដល់ថ្នាក់ទី 12 ដែលរៀននៅសាលារដ្ឋ ត្រូវតែចូលរួមក្នុងកម្មវិធីវាយតម្លៃភាពស្ទាត់ជំនាញភាសាអង់គ្លេសប្រចាំឆ្នាំ ។ ដោយមានការលើកលែងតិចតួច សិស្សជាអ្នកសិក្សាភាសាអង់គ្លេសទាំងអស់ ត្រូវប្រឡងវិញ្ញាសារ ACCESS for ELLs ។

ចំពោះសិស្សដែលស្ថិតក្នុងកម្មវិធីសិក្សាតម្រូវតាមលក្ខណៈបុគ្គល (Individualized Education Program - IEP) ឬផែនការ 504 អាចមានសិទ្ធិទទួលបានការប្រឡងបែបបន្ធូរបន្ថយ ។ ការបន្ធូរបន្ថយចំពោះវិញ្ញាលើក្រដាស គឺមានរួមបញ្ចូលដូចជាការបោះពុម្ពជាអក្សរធំៗ និងការរៀបចំសៀវភៅសម្រាប់ឲ្យសិស្សពិការភ្នែកប្រឡង ។

ចំពោះសិស្សមួយចំនួនដែលមានពិការភាពខួរក្បាលធ្ងន់ធ្ងរ អាចមានសិទ្ធិប្រឡងវិញ្ញាសារ Alternate ACCESS for ELLs ជំនួសឲ្យវិញ្ញាសារ ACCESS for ELLs ។ *សូមអានមគ្គុទ្ទេសក៍អំពីការចូលរួមប្រឡងវិញ្ញាសារ Alternate ACCESS for ELLs* ។ (ចូលទៅកាន់ Districts, Schools and Educators > Statewide Testing > Minnesota Tests ។)

## តើការប្រឡងទាំងនេះត្រូវរៀបចំឡើងដោយរបៀបណា?

សិស្សភាគច្រើនត្រូវប្រឡងវិញ្ញាសារ ACCESS for ELLs ដោយប្រើកុំព្យូទ័រ តែក៏មានការលើកលែងផងដែរ ដោយអាស្រ័យលើកម្រិតថ្នាក់ និងវិស័យនៃជំនាញ (ការអាន ការសរសេរ ការស្តាប់ ឬការនិយាយ) ។

ចំពោះការប្រឡងដោយប្រើក្រដាសនៃវិញ្ញាសារ Alternate ACCESS for ELLs គឺត្រូវធ្វើឡើងដោយសិស្សមួយ មានគ្រូមួយ ។

## តើសិស្សត្រូវត្រៀមខ្លួនយ៉ាងដូចម្តេចដើម្បីប្រឡង?

ចំពោះការប្រឡង ACCESS for ELLs ឬ Alternate ACCESS for ELLs សិស្សទាំងអស់មិនចាំបាច់រៀនត្រៀមអ្វីឡើយ ។ គ្រូនឹងផ្តល់ឱកាសឲ្យសិស្សអាចអនុវត្តការធ្វើតេស្ត ដោយការប្រើសំណួរគំរូសម្រាប់ប្រឡង ដើម្បីឲ្យសិស្សបានដឹងថា ក្នុងថ្ងៃប្រឡង ពួកគេត្រូវធ្វើអ្វីខ្លះ ។

## តើត្រូវធ្វើយ៉ាងដូចម្តេចទើបអាចប្រឡងជាប់?

ចំពោះការប្រឡងវិញ្ញាសារ ACCESS for ELLs ឬ Alternate ACCESS for ELLs គឺមិនមានពិន្ទុជាប់ ឬធ្លាក់ឡើយ ។ ដោយសារការប្រឡងបែបនេះ គឺដើម្បីវាស់វែងកម្រិតសមត្ថភាពយល់ដឹង និងកម្រិតសម្ថភាពការប្រើភាសាអង់គ្លេសរបស់សិស្ស ពួកគេនឹងទទួលបានពិន្ទុបញ្ជាក់ពីភាពស្ទាត់ជំនាញភាសាអង់គ្លេសពីកម្រិត 1–6 ។

## តើវិញ្ញាសារ ACCESS ព្រមទាំង Alternate ACCESS for ELLs វាស់ស្ទង់លើបំណិនអ្វីខ្លះ?

វិញ្ញាសារ ACCESS for ELLs ប្រើសម្រាប់វាស់ស្ទង់ភាពស្ទាត់ជំនាញភាសាអង់គ្លេសក្នុងការអាន ការសរសេរ ការស្តាប់ ព្រមទាំងការនិយាយ ដែលផ្អែកលើ បទដ្ឋាន WIDA ចំពោះការអភិវឌ្ឍន៍ភាសាអង់គ្លេស (English Language Development - ELD) ។ បើអ្នកចង់មើលឯកសារស្តីអំពី បទដ្ឋាន WIDA English Language Development Standards (ចូលទៅកាន់ WIDA > Standards & Instruction > English Language Development (ELD) Standards) ។

វិញ្ញាសារ Alternate ACCESS for ELLs ប្រើសម្រាប់វាស់ស្ទង់បំណិន ការអាន ការសរសេរ ការស្តាប់ ព្រមទាំង បំណិនការនិយាយ ដោយអាស្រ័យលើសូចនាករណ៍វាស់វែងលទ្ធផលសម្រេចបានតាមគំរូផ្សេង (Alternate Model Performance Indicators - AMPIs) ។ បើអ្នកចង់អានឯកសារ AMPIs (ចូលទៅកាន់ WIDA > Assessment > Alternate ACCESS for ELLs) ។

## តើខ្ញុំអាចរកមើលលទ្ធផលប្រឡង ACCESS for ELLs ព្រមទាំង Alternate ACCESS for ELLs របស់កូនខ្ញុំ របស់សាលា និងរបស់មណ្ឌលសិក្សាស្រុក បានដោយរបៀបណា?

សាលារៀនកូនអ្នក នឹងទទួលបានរបាយការណ៍ពិន្ទុរបស់សិស្សម្នាក់ៗ ហើយសាលានឹងបញ្ជូនរបាយការណ៍របស់កូនអ្នកទៅឲ្យអ្នក ។ របាយការណ៍នេះ បង្ហាញពីលទ្ធផលសម្រេចបានពីការប្រឡង ដោយបូករួមទាំងពិន្ទុពីវិស័យនីមួយៗចំពោះមុខវិជ្ជាភាសាអង់គ្លេស ក៏ដូចជាពិន្ទុមធ្យមផងដែរ ។

លទ្ធផលប្រឡងរបស់សាលា និងមណ្ឌលសិក្សាស្រុកមានផ្សាយនៅក្នុងប័ណ្ណរបាយការណ៍រដ្ឋមីណេសូតា (Minnesota Report Card) នៅក្នុងវគ្គមជ្ឈមណ្ឌលទិន្នន័យ (Data Center) នៃគេហទំព័រ MDE ។ សូមចូលទៅកាន់ផ្នែកប័ណ្ណរបាយការណ៍រដ្ឋមីណេសូតា (Minnesota Report Card) នៃគេហទំព័រ MDE (ចូលទៅកាន់ Data Center > Minnesota Report Card) ។

---


*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ៖*

Statewide Testing
mde.testing@state.mn.us

Minnesota Department of Education
1500 Highway 36 West
Roseville, MN 55113-4266
http://education.state.mn.us



*ខែកញ្ញា ឆ្នាំ 2016*